**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៥៣ **អយក.** សណន

ក្រសួង... រដ្ឋបាល

ចូល លេខ: ៨១៩៨ មកដល់ថ្ងៃទី១៧ ខែ១២ ឆ្នាំ១៩ ម៉ោង ៣:៤៣

**សេចក្តីណែនាំ**

**ស្តីពី**

**ការគ្រប់គ្រងគ្រូបង្រៀន**

**យោង៖**

- ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែតុលាឆ្នាំ១៩៩៤
- ច្បាប់ស្តីពីការវិសោធនកម្ម មាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩
- ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីសហលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីសហលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីសហលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម
- អនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀន ក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ
- អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

ដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀននៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ទាំងគ្រូបង្រៀនក្របខណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល និងគ្រូបង្រៀនថ្នាក់គួប ចាប់ពីឆ្នាំសិក្សា ២០១៩ - ២០២០ ក្រសួងអប់រំ យុវជន និងកីឡាដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

## ១. ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ

- គ្រឹះស្ថានសិក្សាសាធារណៈត្រូវគ្រប់គ្រង និងបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ តាមសេចក្តីណែនាំលេខ ២០ អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០១៨ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ
    - នាយកសាលាមានសេវាបង្រៀន ចំពោះសាលាតូច តិចជាងឬស្មើ៣ថ្នាក់
    - ចំនួនបណ្ណារក្ស ត្រូវគិតតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការត្រួតពិនិត្យនិងរៀបចំស្វ័យប្រកាសសាលារៀន ដែលមានតម្រូវការគ្រូបង្រៀនតាមប្រភេទក្របខណ្ឌនិងមុខវិជ្ជាជំនាញនិងត្រូវសហការជាមួយនាយកដ្ឋានបុគ្គលិក ក្នុងការបែងចែកតួលេខក្របខណ្ឌឱ្យទៅដល់សាលារៀនដែលកំពុងខ្វះគ្រូបង្រៀន
- គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅដែលសាមីខ្លួនបានជ្រើសរើស ដោយមិនអនុវត្តការផ្តល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ទាំងនៅថ្នាក់ជាតិ និងរាជធានី ខេត្ត
- ចុះពិនិត្យការអនុវត្តនិយាម (ធៀបជាមួយនឹងស្វ័យប្រកាសរបស់សាលារៀន)
- ក្រសួងនឹងពិនិត្យលទ្ធភាពស្នើគោលការណ៍ចុះឈ្មោះគរុសិស្ស និស្សិតក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ និងស្នើសុំគោលការណ៍ផ្តល់ក្របខណ្ឌបណ្តោះអាសន្ន
- ក្រសួងនឹងពិនិត្យស្នើគោលការណ៍ផ្តល់បៀវត្សមូលដ្ឋានដល់គរុសិស្ស គរុនិស្សិត បន្ទាប់ពីបានប្រឡងជាប់។

## ១.១ ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា

- គ្រឹះស្ថានសិក្សានីមួយៗត្រូវធ្វើការវិភាគនិងព្យាករអំពីតម្រូវការធនធានមនុស្សតាមប្រភេទក្របខណ្ឌនិងមុខវិជ្ជាជំនាញឱ្យបានច្បាស់លាស់មុននឹងលើកសំណើសុំគ្រូបង្រៀនបន្ថែមរួមបញ្ចូលទាំងគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនពីរថ្នាក់ពីរពេល ។ល។
- ការវិភាគនិងព្យាករអំពីតម្រូវការធនធានមនុស្សត្រូវអនុលោមតាម សេចក្តីណែនាំលេខ២០ អយក.សណន ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងសេចក្តីណែនាំលេខ៤៩៨ មស.សណន ស្តីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា នៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ របស់ក្រសួងមុខងារសាធារណៈ
- គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចេញរបស់បុគ្គលិក/គ្រូបង្រៀន ដើម្បីធានាថា ការសុំផ្លាស់ចេញមិនប៉ះពាល់ដល់សេវាបង្រៀន នៅក្នុងឆ្នាំសិក្សាបច្ចុប្បន្ន និងពេលអនាគត
- គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចូល ឬការដាក់ពាក្យសុំប្រឡងចូល ដើម្បីធានាថា បុគ្គលិក / គ្រូបង្រៀនដែលនឹងត្រូវបញ្ជូនមកនឹងបំពេញនូវតម្រូវការធនធានមនុស្សសម្រាប់ពេលបច្ចុប្បន្ន និងមិននៅសល់ក្នុងពេលអនាគត។

## ១.២ ការរៀបចំផែនការក្របខណ្ឌប្រចាំឆ្នាំ

- អង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិត្រូវសហការគ្នាដើម្បីរៀបចំផែនការមេស្តីពីតម្រូវការនិងការផ្គត់ផ្គង់គ្រូបង្រៀន ដោយផ្អែកលើចំណោលសិស្ស
- ប្រមូលផ្តុំទិន្នន័យគ្រូបង្រៀន គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនចូលនិវត្តន៍ គ្រូបង្រៀនផ្លាស់ចេញពីក្របខណ្ឌ និងមរណជន
- រៀបចំសំណើសុំក្របខណ្ឌថ្មី គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរវេន ដើម្បីដាក់ជូនក្រសួងមុខងារសាធារណៈ
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវអនុវត្តដូចគ្នានឹងចំណុចខាងលើ ដោយសហការជាមួយការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា។

## ១.៣ ការជ្រើសរើសបុគ្គលិកចូលក្របខណ្ឌ

- បន្តអនុវត្តវិធានការជ្រើសរើសសាលារៀន នៅមុនពេលដាក់ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់ប្រភេទក្របខណ្ឌ
- បន្តប្រឡងជ្រើសរើសក្របខណ្ឌថ្មី ទៅតាមប្រភេទក្របខណ្ឌ មុខវិជ្ជាជំនាញ
- ផ្តល់អាទិភាពដល់បេក្ខជនមកពីតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងបេក្ខជនដែលជ្រើសរើសខេត្ត ដាច់ស្រយាល
- បន្តប្រឡងជ្រើសរើសបញ្ចូលក្របខណ្ឌចំពោះបេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត
- ការជ្រើសរើសគ្រូបន្ថែម គួរផ្តល់អាទិភាពដល់ការដោះស្រាយបញ្ចប់ការប្រើប្រាស់គ្រូថ្នាក់គួបបីកម្រិត ព្រមទាំងកាត់បន្ថយថ្នាក់គួបពីរកម្រិត និងថ្នាក់ពីរវេន 

- ការជ្រើសរើសគ្រូថ្មី ជំនួសគ្រូចូលនិវត្តន៍ ជាគោលការណ៍គួរបញ្ឈប់ការផ្តល់ទៅកន្លែងដែលកំពុងលើសស្រាប់
- ការប្រឡងជ្រើសរើសគ្រូក្របខណ្ឌថ្មីគួរពិនិត្យជម្រើសប្រឡងជ្រើសរើសក្នុងចំណោមសិស្សក្នុងខេត្តគោលដៅនោះ ដើម្បីកាត់បន្ថយនិន្នាការនៃការស្នើសុំផ្លាស់ប្តូរទីកន្លែងធ្វើការ
- ការបែងចែកក្របខណ្ឌថ្មីសម្រាប់ការប្រឡងជ្រើសរើសត្រូវរៀបចំបែងចែកតាមដំណាក់កាលៈ
    - បន្ទាប់ពីទទួលបានតួលេខសម្រាប់ការប្រឡងជ្រើសរើសក្របខណ្ឌប្រចាំឆ្នាំ ក្រសួងត្រូវប្រជុំពិនិត្យការបែងចែកតួលេខជាកញ្ចប់ឱ្យទៅដល់រាជធានី ខេត្តនីមួយៗ ទាំងគ្រូបង្រៀនកម្រិតឧត្តម កម្រិតមូលដ្ឋាន និងបឋម-មត្តេយ្យសិក្សាដោយផ្អែកលើស្ថានភាពខ្វះជាក់ស្តែង
    - បន្ទាប់ពីទទួលបានតួលេខរួចហើយ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តនីមួយៗត្រូវយកទៅបែងចែកឱ្យទៅដល់សាលារៀនដែលកំពុងខ្វះជាក់ស្តែងតាមប្រភេទក្របខណ្ឌនិងតាមមុខវិជ្ជាជំនាញចំពោះគ្រូបង្រៀនកម្រិតមូលដ្ឋាន និងកម្រិតឧត្តម ដោយបញ្ជាក់ឈ្មោះសាលារៀនដែលមានតម្រូវការឱ្យបានច្បាស់លាស់ និងលើកសំណើមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈនាយកដ្ឋានបុគ្គលិក ដើម្បីសុំការសម្រេច
    - បន្ទាប់ពីទទួលបានសំណើ ស្តីពីតម្រូវការគ្រូបង្រៀនរបស់រាជធានី ខេត្ត ក្រសួងត្រូវរៀបចំប្រជុំលើកទី២ ដើម្បីពិនិត្យនិងសម្រេច ហើយបញ្ជូនត្រឡប់ទៅវិញដើម្បីអនុវត្តសម្រាប់ការប្រឡងជ្រើសរើស។

## ២. ការដោះស្រាយស្ថានភាពលើសឬខ្វះគ្រូបង្រៀន

- ពង្រឹងការអនុវត្តសេចក្តីណែនាំលេខ ២៣ អយក.សណន ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពី ការបែងចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី (ប៉ុន្តែគួរមានការកែសម្រួលចំណុចមួយចំនួន ដូចខាងក្រោម)
    - ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានី ខេត្ត គណៈកម្មការជ្រើសរើសប៉ុស្តិ៍
    - គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យា ទៅបម្រើការនៅសាលារៀន ដែលបានជ្រើសរើស ត្រូវទៅបម្រើការនៅទីនោះ
    - បញ្ឈប់ការប្តូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច
    - គ្រូបង្រៀនចេញថ្មី ដែលមិនគោរពតាមលិខិតបង្គាប់ការ ឬលិខិតឧទ្ទេសនាម នឹងត្រូវស្នើផ្អាកបៀវត្ស ឬស្នើលុបឈ្មោះចេញពីក្របខណ្ឌភ្លាម។

## ២.១ សាលារៀនលើសគ្រូបង្រៀន

- *ករណីរាជធានីភ្នំពេញ*
    - អនុវត្តសាកល្បងនៅរាជធានីភ្នំពេញដោយមានការពិនិត្យឱ្យបានហ្មត់ចត់តួលេខគ្រូបង្រៀនដែលមានសេវាបង្រៀនមិនគ្រប់តាមនិយាមកំណត់ និងអាសយដ្ឋានបច្ចុប្បន្នរបស់គ្រូបង្រៀនទាំងអស់នោះ ដើម្បីស្នើពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូបង្រៀន នៅជិតលំនៅដ្ឋានរបស់ពួកគាត់។
- *ករណីខេត្តផ្សេងទៀត*
    - បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ
    - ស្នើសុំគោលការណ៍បង្កើនប្រាក់ឧបត្ថម្ភម្តងគត់ដល់គ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ
    - សុំគោលការណ៍ផ្តល់ប្រាក់បំណាច់មុខងារពិសេសដល់គ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់ជួបការលំបាកខ្លាំង។

## ២.២ សាលារៀនខ្វះគ្រូបង្រៀន

- ធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតបឋមសិក្សាដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងត្រូវផ្តល់អាទិភាពឱ្យគ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលខ្វះគ្រូ ដោយតម្រូវឱ្យសាមីខ្លួនជ្រើសរើសសាលារៀន និងមុខវិជ្ជាមុននឹងដាក់ពាក្យសុំចុះឈ្មោះ
- ពិភាក្សាជាមួយក្រសួងពាក់ព័ន្ធដើម្បីរកលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភម្តងគត់សម្រាប់ការពង្រាយគ្រូបង្រៀនថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ការស្នើបញ្ចូលក្របខណ្ឌ (ទាំងគ្រូក្របខណ្ឌនិងគ្រូបង្រៀនជាប់កិច្ចសន្យា) ត្រូវធ្វើឡើងដោយផ្អែកលើផែនការគ្រប់ជ្រុងជ្រោយ ច្បាស់លាស់ និងស្របតាមគោលការណ៍កំណត់ ដោយចៀសវាងនូវការស្នើសុំបន្ថែមក្នុងឆ្នាំ ដែលធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅដោយមិនមានតម្លាភាព និងប្រសិទ្ធភាព

### ២.២.១. គ្រូបង្រៀនជាប់កិច្ចសន្យា

- គ្រឹះស្ថានសិក្សាសាធារណៈ (បឋមសិក្សា) ត្រូវធ្វើស្វ័យប្រកាសអំពី ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ស្របតាមសេចក្តីណែនាំលេខ ៤៩៨ មស.សណន របស់ក្រសួងមុខងារសាធារណៈ
- ការប្រឡងជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវរៀបចំដោយមានលក្ខណៈទន់ភ្លន់ និងដោយផ្តល់អាទិភាពពិន្ទុចំពោះបេក្ខជនដែលស្ម័គ្រចិត្តទៅបម្រើការនៅតាមតំបន់ដាច់ស្រយាល និងជួបការលំបាក
- ពង្រឹងការអនុវត្តគោលការណ៍ណែនាំស្តីពីការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ដោយត្រូវជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា តាមការចាំបាច់ជាក់ស្តែងក្នុងឆ្នាំនីមួយៗសម្រាប់សាលារៀនដែលខ្វះគ្រូ
- គ្រូបង្រៀនជាប់កិច្ចសន្យាអាចប្រឡងចូលក្របខណ្ឌរដ្ឋដែលបានកំណត់នៅក្នុងលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌគ្រូបង្រៀន
- ការស្នើសុំចូលក្របខណ្ឌជាស្វ័យប្រវត្តិ របស់គ្រូបង្រៀនជាប់កិច្ចសន្យាមិនត្រូវបានអនុញ្ញាតឡើយ
- ផ្តល់សិទ្ធិឱ្យនាយកសាលាដែលមានតម្រូវការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ
- សាលាគរុកោសល្យខេត្តនីមួយៗត្រូវមានផែនការបំប៉នគ្រូបង្រៀនជាប់កិច្ចសន្យាដែលជ្រើសរើសថ្មី
- ពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការធ្វើផែនការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាដើម្បីជៀសវាងការស្នើសុំបន្ថែម
- ពិនិត្យឡើងវិញគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ
- សុំគោលការណ៍ជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា១ឆ្នាំមុន ដោយមិនមានការដោះដូរ និងបន្តដោយស្វ័យប្រវត្តិតាមរយៈ
    - ការសិក្សានិងវាយតម្លៃសេវាបង្រៀនរបស់គ្រូបង្រៀនជាប់កិច្ចសន្យា
    - ការធ្វើតេស្ត / ប្រឡង
    - ការបណ្តុះបណ្តាលនិងចាត់ឱ្យបង្រៀននៅចំទីតាំង
- សាលារៀនត្រូវជ្រើសរើសគ្រូកិច្ចសន្យានិងត្រូវសុំទិដ្ឋាការពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមុខងារសាធារណៈ ដើម្បីធានាគុណភាព
- ស្នើសុំក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្ទេរប្រាក់ឧបត្ថម្ភទៅកាន់គណនីរបស់សាលាផ្ទាល់ ប្រការនេះនឹងធានាការបើកទៀងទាត់ និងទាន់ពេល
- កំណត់ចំនួនជ្រើសរើសគ្រូបង្រៀនកិច្ចសន្យាមិនឱ្យលើសពី ១០,០០០ នាក់ ក្នុង១ឆ្នាំ។ ចំពោះគ្រូបង្រៀនជាប់កិច្ចសន្យា បើមិនអាចកាត់បន្ថយបាន ក៏មិនគួរឱ្យកើនថែមទៀតទេ។ បើចាំបាច់ខ្លាំង ការជ្រើសរើសគ្រូបង្រៀន ២

ជាប់កិច្ចសន្យា គួរផ្តល់អាទិភាពដល់គ្រូចូលនិវត្តន៍ដែលមានសមត្ថភាព និងស្ម័គ្រចិត្តបន្តបង្រៀន (ក្រៅពីជ្រើសរើសសិស្ស និស្សិត ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ)

- ស្នើសុំគោលការណ៍អនុញ្ញាតឱ្យមន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត មានសិទ្ធិសម្រេចលើករណី ជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាដើម្បីជំនួស គ្រូបង្រៀនជាប់កិច្ចសន្យា មរណភាព និងលំហែមាតុភាព
- ស្នើសុំគោលការណ៍បន្តផ្តល់ប្រាក់ឧបត្ថម្ភក្នុងពេលវិស្សមកាលដល់គ្រូបង្រៀនជាក់កិច្ចសន្យាដែលជ្រើសរើសចេញពីគ្រូបង្រៀនចូលនិវត្តន៍ និងនិស្សិតដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើង។

**២.២.២. គ្រូបង្រៀនថ្នាក់គួប**

- គ្រឹះស្ថានសិក្សាសាធារណៈ (បឋមសិក្សា) ត្រូវធ្វើស្វ័យប្រកាសអំពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់គួប ស្របតាមសេចក្តីណែនាំលេខ ៤៩៨ មស.សណន របស់ក្រសួងមុខងារសាធារណៈ
- ពង្រឹងការអនុវត្តការកិច្ចថ្នាក់គួប តាមមាត្រា ១៨ នៃអនុក្រឹត្យលេខ ៣០៩ អនក្រ.បក ស្តីពី ការគ្រប់គ្រងនិងចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤
  - កង្វះបន្ទប់រៀនសម្រាប់សេវាបង្រៀនដល់សិស្សនៅកម្រិតថ្នាក់ណាមួយ
  - ក្នុងករណីគ្រូបង្រៀនជាប់កិច្ចសន្យាមិនអាចអនុវត្តបាន
  - កង្វះបន្ទប់រៀននិងចំនួនសិស្សមិនគ្រប់តាមនិយាម
  - គ្រឹះស្ថានបឋមសិក្សាសាធារណៈនោះមិនគ្រប់កម្រិត
- កាត់បន្ថយការប្រើគ្រូបង្រៀនថ្នាក់គួប
- លុបបំបាត់ការបង្រៀនថ្នាក់គួបបីកម្រិតថ្នាក់
- អធិការកិច្ចលទ្ធផលនៃការបង្រៀនថ្នាក់គួប។

**២.២.៣ គ្រូបង្រៀនពីរវេន**

- គ្រឹះស្ថានសិក្សាសាធារណៈ(បឋមសិក្សា) ត្រូវធ្វើស្វ័យប្រកាសអំពី ការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន ស្របតាមសេចក្តីណែនាំលេខ ៤៩៤ មស.សណន របស់ក្រសួងមុខងារសាធារណៈ
- កាត់បន្ថយការប្រើគ្រូបង្រៀនពីរវេន
- អធិការកិច្ចលទ្ធផលការបង្រៀនថ្នាក់គួប។

**២.២.៤. ការប្រើប្រាស់ប្រាក់ម៉ោងបន្ថែម (អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៧)**

- ម៉ោងបន្ថែមសំដៅដល់ចំនួនម៉ោងដែលគ្រូបង្រៀនបានបង្រៀន និងបំពេញការងារគរុកោសល្យ ព្រមទាំងការងារពាក់ព័ន្ធនឹងការបង្រៀនលើសពីចំនួនម៉ោងកំណត់
  - គ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុត៤៨ម៉ោងក្នុង១ខែ ក្នុងគ្រឹះស្ថានសិក្សាសាធារណៈដែលសាមីជនកំពុងបំពេញការងារឬគ្រឹះស្ថានសិក្សាសាធារណៈផ្សេងទៀត
  - មន្ត្រីរាជការមិនមែនជាគ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុតចំនួន ៣២ ម៉ោង ក្នុង១ខែ។
- គ្រឹះស្ថានសិក្សាសាធារណៈដែលអាចអនុវត្តរបបម៉ោងបន្ថែមបាន លុះត្រាតែៈ
  - បានគ្រោងឥណទានថវិកាសម្រាប់របបម៉ោងបន្ថែម
  - ពុំមានគ្រូបង្រៀនគ្រប់គ្រាន់ ដើម្បីបង្រៀនមុខវិជ្ជាស្របតាមនិយាមកំណត់
  - ត្រូវមានការអនុញ្ញាតជាមុនពីក្រសួងសាមី

- ប្រើប្រាស់របបម៉ោងបន្ថែមក្នុងរង្វង់ឥណទានថវិកាដែលផ្តល់ឱ្យតែប៉ុណ្ណោះ។

- អ្នកមានសិទ្ធិបង្រៀនម៉ោងបន្ថែម លុះត្រាតែ ៖
  - ជាមន្ត្រីរាជការជាគ្រូបង្រៀន ប្រចាំគ្រឹះស្ថានសិក្សា
  - ជាមន្ត្រីរាជការមិនមែនជាគ្រូបង្រៀន ដែលត្រូវបានជ្រើសរើសឬចាត់តាំងឱ្យបង្រៀនក្នុងគ្រឹះស្ថានសិក្សា
  - មានលិខិតបង្គាប់ការជាផ្លូវការរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអនុញ្ញាតឱ្យបង្រៀនម៉ោងបន្ថែម
  - ជាគ្រូបង្រៀនបានអនុវត្តពេញលេញការបង្រៀនតាមរបបម៉ោងកំណត់។
- គ្រឹះស្ថានសិក្សាសាធារណៈដែលមានប្រភពចំណូលប្រចាំឆ្នាំផ្ទាល់របស់ខ្លួនពីការបង់ថ្លៃរបស់សិស្ស សកម្មភាពពាណិជ្ជកម្ម ឬអំណោយផ្សេងៗ សរុបលើសពី ៥០% នៃថវិកាប្រចាំឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យមានការផ្តល់ប្រាក់ម៉ោងបន្ថែមពីថវិកាជាតិឡើយ។

## ៣. ការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់គ្រូបង្រៀន

- ទប់ស្កាត់ការផ្លាស់ប្តូរគ្រូបង្រៀនចូលសាលារៀនលើសគ្រូ ទោះបីតាមសហព័ទ្ធក៏ដោយ
- អនុញ្ញាតឱ្យផ្លាស់ប្តូរទីកន្លែងធ្វើការឆ្លងរាជធានី ខេត្ត ប៉ុន្តែសាមីខ្លួនត្រូវជ្រើសរើសសាលារៀនជាមុនសិន ហើយត្រូវមានយោបល់យល់ព្រមទទួលពីនាយកសាលារៀន និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដែលត្រូវផ្លាស់ចូល ទើបអាចដាក់ពាក្យសុំផ្លាស់ប្តូរបាន
- អនុញ្ញាតឱ្យផ្ទេរក្របខណ្ឌចេញក្រៅក្រសួង ចំនួន ៥០ នាក់ ក្នុង១ឆ្នាំ ដោយមិនគិតការផ្ទេរជាករណីដោយឡែក
- មិនអនុញ្ញាតឱ្យគ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌប្តូរគ្រឹះស្ថានសិក្សាដែលសាមីខ្លួនបានជ្រើសរើស
- ការផ្លាស់ប្តូរពីរាជធានី ខេត្ត ចូលអង្គភាពនានាក្រោមឱវាទទីស្តីការក្រសួងត្រូវឆ្លងកាត់ការប្រឡង វាស់ស្ទង់សមត្ថភាព និងឆ្លងកាត់ការធ្វើសម្ភាសន៍ដោយផ្ទាល់ពីប្រធានអង្គភាពដែលត្រូវផ្លាស់ចូល។

### ៣.១ ការផ្លាស់ប្តូរតាមសហព័ទ្ធ

- ត្រូវត្រួតពិនិត្យឯកសារឱ្យបានច្បាស់លាស់ (ចៀសវាងការរៀបការក្លែងក្លាយ)
- អនុញ្ញាតឱ្យផ្លាស់ប្តូរតាមសហព័ទ្ធចូលក្រោមឱវាទទីស្តីការក្រសួង ប៉ុន្តែមិនអនុញ្ញាតផ្លាស់ចូលក្នុងអង្គភាពតែមួយ
- គ្រូបង្រៀនចេញថ្មីដែលសុំប្តូររាជធានី ខេត្ត តាមសហព័ទ្ធជាមន្ត្រីរាជការ អនុញ្ញាតឱ្យប្តូរបន្ទាប់ពីសាមីខ្លួនបានបញ្ចប់កម្មសិក្សាដោយជោគជ័យ។

ទទួលបានសេចក្តីណែនាំនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង និងលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព។

ថ្ងៃចន្ទ ៥ រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

<u>កន្លែងទទួល៖</u>
-ក្រសួងមុខងារសាធារណៈ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
" ដើម្បីជូនជ្រាប "
-គ្រប់អង្គភាព ដើម្បីសហការអនុវត្ត
-កាលប្បវត្តិ
-ឯកសារ នា. បុគ្គលិក

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**